ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅប្រទេសជប៉ុន ជួយសង្គ្រោះ និងទាមទារប្រាក់សំណង ជូនកម្មសិក្សាការីខ្មែរចំនួន៥នាក់

------------

បន្ទាប់ពីមានការស្នើសុំអន្តរាគមន៍ពីកម្មសិក្សាការីខ្មែរចំនួន៥នាក់ តាមរយៈទំព័រ Facebook របស់ស្ថានទូត កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ជប៉ុន** បានសហការជាមួយនគរបាលខេត្តTochigi ដែលមានចំងាយប្រមាណ១១០គីឡូម៉ែត្រពីទីក្រុងតូក្យូ ដើម្បីចុះដល់កន្លែងដែលមេខ្យល់រៀបចំអោយកម្មសិក្សាការីទាំង៥នាក់ស្នាក់នៅ។

ក្រោយពីបានផ្តល់ព័ត៌មានលំអិតដល់ក្រុមនគរបាលរួច ស្ថានទូតបាននាំពួកគេមកស្នាក់នៅបណ្តោះអាសន្នក្នុងស្ថានទូត និងបានសាកសួរព័ត៌មានលំអិតអំពីកន្លែងការងារ និងលក្ខខណ្ឌការងារដែលពួកគេបានធ្វើការកន្លងមក និងមូលហេតុដែលចាញ់បោកមេខ្យល់។

ក្នុងគោលបំណងការពារផលប្រយោជន៍ពលរដ្ឋខ្មែរ ស្ថានទូតបានទាក់ទងទៅថៅកែក្រុមហ៊ុន (ជាលក្ខណៈគ្រួសារ) នៅខេត្តTochigi ដើម្បីដោះស្រាយបញ្ហាប្រាក់បៀវត្ស ដែលថៅកែបានកិបកេងប្រាក់ម៉ោងនិងចំនួនធ្វើការលើសម៉ោងកន្លងមក ជូនកម្មសិក្សាការី ហើយទទួលលទ្ធផលដូចខាងក្រោម៖

១- កញ្ញា តូច សុជា អាយុ៣១ឆ្នាំ មកពីខេត្តស្វាយរៀង ទទួលបានសំណងសរុបចំនួន ៤.៦៤០.៩៦៥ យ៉េន (ប្រមាណជា៤០.៣៥៦ ដុល្លារអាមេរិក)

២- កញ្ញា អឿន តុលា អាយុ៣០ឆ្នាំ មកពីខេត្តពោធិ៍សាត់ ទទួលបានសំណងសរុបចំនួន ៣.០៧១.៧៧៦ យ៉េន (ប្រមាណជា២៦.៧១១ ដុល្លារអាមេរិក)

៣- កញ្ញា ម៉ាប់ រ័ត្ន អាយុ៣០ឆ្នាំ មកពីខេត្តពោធិ៍សាត់ ទទួលបានសំណងសរុបចំនួន ២.៧៣៧.៥៦២ យ៉េន (ប្រមាណជា២៣.៨០៤ ដុល្លារអាមេរិក)

៤- កញ្ញា ហ៊ុន់ ផាណា អាយុ២៤ឆ្នាំ មកពីខេត្តពោធិ៍សាត់ ទទួលបានសំណងសរុបចំនួន ៦៦៧.៣០១ យ៉េន (ប្រមាណជា៥៨០០ ដុល្លារអាមេរិក)

៥- កញ្ញា គឹម អ៊ិញ អាយុ២៧ឆ្នាំ មកពីខេត្តតាកែវ ទទួលបានសំណងសរុបចំនួន ៦៦៧.៣០១ យ៉េន (ប្រមាណជា៥៨០០ ដុល្លារអាមេរិក)។

ដោយសារប្រាក់សំណងមានចំនួនច្រើន ថៅកែក្រុមហ៊ុនបានស្នើសុំបង់សងជាដំណាក់កាល និងសន្យាបង់អោយអស់ក្នុងអំឡុងឆ្នាំ២០១៧។ ចំពោះការសងបន្តនេះ ក្រុមហ៊ុននឹងធ្វើប្រាក់ចូលគណនីរបស់កម្មសិក្សាការីផ្ទាល់តែម្តង ហើយក្រុមហ៊ុននឹងរាយការណ៍ជូនស្ថានទូត ដើម្បីស្ថានទូតអាចតាមដាន និងក្រើនរំលឹកដល់ក្រុមហ៊ុនរហូតដល់សងគ្រប់ចំនួន។

នគរបាលខេត្តTochigi បានសាកសួរព័ត៌មានបន្ថែមពីកម្មសិក្សាការីនៅស្ថានទូត ដើម្បីមានវិធានការចំពោះមេខ្យល់ចំនួន៣នាក់ ក្នុងនោះក៏មានអតីតកម្មសិក្សាការីខ្មែរម្នាក់(នារី) ដែលបានរត់ចោលក្រុមហ៊ុន និងក្លាយជាអ្នកអូសទាញកម្មសិក្សាការីដទៃទៀត អោយបោះបង់ចោលកន្លែងការងាររបស់ ទៅធ្វើការនៅកន្លែងថ្មីដែលមានប្រាក់ចំណូលច្រើនជាង។

កម្មសិក្សាការីទាំង៥នាក់ បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៤** ខែ**កុម្ភៈ ឆ្នាំ២០១៧** វេលាម៉ោង**១៩:៣៥**នាទី តាមជើងយន្តហោះ Thai Airways លេខ **៥៨៤** ៕

ភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ